ខ្មែរ
(Khmer)

Electoral Commission
SOUTH AUSTRALIA

# ចុះឈ្មោះ និងបោះឆ្នោតនៅ 2026 ការបោះឆ្នោតថ្នាក់រដ្ឋ

## អំពីការបោះឆ្នោតថ្នាក់រដ្ឋ

ការបោះឆ្នោតថ្នាក់រដ្ឋ គឺជារបៀបដែលប្រជាជននៅរដ្ឋអូស្ត្រាលីខាងត្បូងជ្រើសរើសបុគ្គលដែលនឹងក្លាយជាតំណាងនៅក្នុងសភារដ្ឋអូស្ត្រាលីខាងត្បូង។ ការបោះឆ្នោតនេះរៀបចំឡើងរៀងរាល់ 4 ឆ្នាំម្តង នៅថ្ងៃសៅរ៍ទីបីក្នុងខែមីនា។

## តើខ្ញុំត្រូវចុះឈ្មោះបោះឆ្នោតដោយរបៀបណា?

នៅពេលអ្នកចុះឈ្មោះ យើងចុះឈ្មោះអ្នកនៅក្នុងបញ្ជីមនុស្សបោះឆ្នោត។ នៅពេលអ្នកបោះឆ្នោត អ្នកជ្រើសរើសនរណាដែលជាផ្នែកនៃសភា។

ការចុះឈ្មោះ ឬធ្វើបច្ចុប្បន្នកម្មព័ត៌មានរបស់អ្នកគឺងាយស្រួល។ សូមចូលមើលវេបសាយរបស់យើងនៅ៖
ecsa.sa.gov.au
ហៅទូរសព្ទឥតគិតថ្លៃទៅលេខ៖ 1300 655 232

**អ្នក<u>ត្រូវតែ</u>ចុះឈ្មោះបោះឆ្នោត ប្រសិនបើអ្នក៖**

- **បានរស់នៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូងយ៉ាងហោចណាស់មួយខែ។**
- **មានអាយុលើសពី 18 ឆ្នាំ**
- **ជាពលរដ្ឋអូស្ត្រាលី**

ការចុះឈ្មោះមានសុពលភាពសម្រាប់ការបោះឆ្នោតថ្នាក់រដ្ឋ ថ្នាក់សហព័ន្ធ និងថ្នាក់មូលដ្ឋាន។ សូមកុំភ្លេចធ្វើបច្ចុប្បន្នកម្មព័ត៌មានរបស់អ្នក ប្រសិនបើអ្នកផ្លាស់ប្តូរផ្ទះ ឬប្តូរឈ្មោះរបស់អ្នក។

## តើខ្ញុំបោះឆ្នោតនៅកន្លែងបោះឆ្នោតដោយរបៀបណា?

អ្នកមានជម្រើសងាយស្រួលជាច្រើនដើម្បីបោះឆ្នោតនៅពេលណាដែលអ្នកចង់។  ទាំងនេះរួមមានការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ឬការបោះឆ្នោតមុនពេលកំណត់នៅមណ្ឌលបោះឆ្នោតមុនពេលកំណត់ ឬការដាក់ស្នើសុំបោះឆ្នោតតាមប្រៃសណីយ៍។ មធ្យោបាយងាយស្រួលបំផុតដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត គឺនៅកន្លែងបោះឆ្នោតនៅជិតកន្លែងដែលអ្នករស់នៅ។

ប្រសិនបើអ្នកមានការរឹតត្បិតលើការចល័ត ឬពិការភាព ឬកំពុងថែទាំនរណាម្នាក់ដែលមានការរឹតត្បិតលើការចល័ត ឬពិការភាព អ្នកអាចពិនិត្យមើលព័ត៌មានសម្របសម្រួលលទ្ធភាពនៃកន្លែងបោះឆ្នោតនៅលើវេបសាយ ecsa.sa.gov.au។

មុនថ្ងៃបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតរដ្ឋអូស្ត្រាលីខាងត្បូងនឹងផ្តល់ជូនអ្នកនូវព័ត៌មានជាលាយលក្ខណ៍អក្សរ អំពីទីតាំងកន្លែងបោះឆ្នោតដែលនៅជិតអ្នកបំផុត។

អ្នកនឹងទទួលបានប័ណ្ណ EasyVote មួយ ដើម្បីយកមកជាមួយនៅពេលអ្នកបោះឆ្នោត។ អ្នកក៏អាចស្វែងរកព័ត៌មានអំពីការិយាល័យបោះឆ្នោតផងដែរ នៅលើវេបសាយ ecsa.sa.gov.au។

**ម៉ោងធ្វើការនៅកន្លែងបោះឆ្នោត៖ 8:00 ព្រឹក - 6:00 ល្ងាច នៅថ្ងៃបោះឆ្នោត។**

**1. នៅពេលអ្នកអញ្ជើញទៅកន្លែងបោះឆ្នោត អ្នកនឹងត្រូវបានគេសួររកឈ្មោះ អាសយដ្ឋាន និងសួរថា “*តើអ្នកធ្លាប់បានបោះឆ្នោត ក្នុងការបោះឆ្នោតនេះពីមុនឬទេ?*”។**

ដើម្បីធ្វើឱ្យការកំណត់អត្តសញ្ញាណរបស់អ្នកកាន់តែងាយស្រួល និងឆាប់រហ័ស អ្នកអាចយកប័ណ្ណ EasyVote របស់អ្នក ឬឯកសារផ្សេងទៀតដែលមានឈ្មោះ និងអាសយដ្ឋានរបស់អ្នកមកជាមួយ។

**2. ឈ្មោះរបស់អ្នកនឹងត្រូវបានពិនិត្យក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ហើយអ្នកនឹងទទួលបានសន្លឹកឆ្នោតចំនួនពីរ៖ មួយសម្រាប់សភាតំណាងរាស្ត្រ (ពណ៌បៃតង) និងមួយទៀតសម្រាប់ក្រុមប្រឹក្សានីតិបញ្ញត្តិ (ពណ៌ស)។**

**3. សូមយកសន្លឹកឆ្នោតទៅកន្លែងបោះឆ្នោត ដែលអ្នកអាចបំពេញសន្លឹកឆ្នោតរបស់អ្នកជាលក្ខណៈឯកជនបាន។**

ការបោះឆ្នោតរបស់អ្នកគឺសម្ងាត់។ ប៉ុន្តែប្រសិនបើអ្នកត្រូវការជំនួយ សូមស្នើសុំពីបុគ្គលិករៀបចំការបោះឆ្នោត។

**4. នៅពេលអ្នកបានបំពេញសន្លឹកឆ្នោតរបស់អ្នករួចហើយ សូមស៊កវាចូលទៅក្នុងប្រអប់ឆ្នោត។**



# របៀបបំពេញ សន្លឹកឆ្នោត


South Australia

Issuing Officer Initials

**Ballot Paper**

Election of one Member for the House of Assembly

**DISTRICT**

**Number the squares from 1 to 4 in the order of your choice.**

You are not legally obliged to mark the ballot paper.

| | | |
|---|---|---|
| ☐ | CANDIDATE Name | Political Party or Independent |
| ☐ | CANDIDATE Name | Political Party or Independent |
| ☐ | CANDIDATE Name | Political Party or Independent |
| ☐ | CANDIDATE Name | Political Party or Independent |

After voting, fold the ballot paper and place it in the ballot box or declaration envelope

## អ្នកនឹងទទួលបានសន្លឹកឆ្នោតពីរ៖

## 1. សន្លឹកឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រ

នៅលើសន្លឹកឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រពណ៌បៃតង អ្នកត្រូវតែដាក់លេខនៅក្នុងប្រអប់នីមួយៗជាហូរហែរ ទៅតាមលំដាប់ដែលអ្នកជ្រើសរើស។

1. សូមសរសេរលេខ '1' នៅក្នុងប្រអប់ក្បែរបេក្ខជនដែលអ្នកចង់ចង្អុលបង្ហាញថាជាជម្រើសទីមួយរបស់អ្នក។
2. សូមសរសេរលេខ '2' នៅក្បែរជម្រើសទីពីររបស់អ្នក។
3. សូមសរសេរលេខ '3' នៅក្បែរជម្រើសទីបីរបស់អ្នក។

...ហើយបន្តរហូតដល់អ្នកបានដាក់លេខនៅគ្រប់ប្រអប់។

ប្រសិនបើអ្នកធ្វើខុស សូមកុំបារម្ភ។ សូមគូសឆូតពីលើកំហុសនោះ ហើយសរសេរព័ត៌មានត្រឹមត្រូវនៅក្បែរនោះ ឬអ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីពីមន្ត្រីរៀបចំការបោះឆ្នោតបាន។

**ប្រសិនបើអ្នកធ្វើខុស សូមស្នើសុំជំនួយពីបុគ្គលិកជានិច្ច**

# 2. សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សានីតិប្បញ្ញត្តិ

មានវិធី 2 យ៉ាងដែលអ្នកអាចបោះឆ្នោតបាន - ពីលើបន្ទាត់ដិត ឬពីក្រោមបន្ទាត់នោះ - ***ប៉ុន្តែមិនមែនទាំងពីរនោះទេ។***

## បោះឆ្នោតពីលើបន្ទាត់ដិត៖

ប្រសិនបើអ្នកជ្រើសរើសបោះឆ្នោតពីលើបន្ទាត់ដិត៖

1. **សូមសរសេរលេខ ‘1’ នៅក្នុងប្រអប់ក្បែរគណបក្ស ឬក្រុមបេក្ខជនដែលជាជម្រើសទីមួយរបស់អ្នក។**
2. **សូមសរសេរលេខ ‘2’ នៅក្បែរជម្រើសទីពីររបស់អ្នក** ហើយបន្តធ្វើដូចនេះសម្រាប់គណបក្ស ឬក្រុមបេក្ខជនទាំងប៉ុន្មានតាមដែលអ្នកពេញចិត្ត។

អ្នកមិនចាំបាច់ត្រូវដាក់លេខនៅគ្រប់ប្រអប់នោះទេ។ សូមទុកផ្នែកសេសសល់លើសន្លឹកឆ្នោតឱ្យនៅទទេ។ សូមកុំគូសពីក្រោមបន្ទាត់ដិតក្រាស់។

ដោយការបោះឆ្នោតពីលើបន្ទាត់ដិត សំឡេងឆ្នោតរបស់អ្នកនឹងត្រូវបានរាប់សម្រាប់បេក្ខជននៅក្នុងក្រុម (ឬក្រុមនានា) ដែលអ្នកបានជ្រើសរើស។


South Australia, 2026 Election

**Ballot Paper for the Election of 11 Legislative Councillors**

You may vote in one of two ways. You are not legally obliged to mark the ballot paper.

**If you vote ABOVE the line**

If you vote above the line write the number 1 in the square next to the group of your choice. You can show more choices if you want to by writing numbers in other squares starting with the number 2.
Do not write any numbers below the line.

| A | B | C | D | E |
|---|---|---|---|---|
| Environment First Party | Shine Australia | The People's Party | Farmer's Alliance | Southern Cross Party |

**OR**

**If you vote BELOW the line**

If you vote below the line write the numbers 1 to 12 in the squares next to the names of the candidates in the order of your choice. You can show more choices if you want to by continuing to write numbers in more squares. You don't need to write a number in every square.
Do not write any numbers above the line.

| A | B | C | D | E |
|---|---|---|---|---|
| Lauren Hall | Finn Robinson | Anita Holland | Winston Barker | Naomi Lee |
| Tony Matic | Latika Fischer | Joshua McCall | Nina Harris | Felix Barker |
| Jane Nguyen | Andy McMahon | Imane Caskey | John Thompson | Jennie Rodriguez |
| Oliver Bloom | Helen Park | Ahren Patel | Rachel McKinnon | Rory Lane |
| Sasha Crown | James Ludwig | Vanessa Hollow | Jeremy Choi | Katrina Sebastian |
| Travis Alves | Ophelia Knight | Porter Smith | Courtney Wilson | Noah Stringer |

Issuing Officer Initials

After voting, fold the ballot paper and place it in the ballot box or in the envelope provided.

## បោះឆ្នោតពីក្រោមខ្សែបន្ទាត់ដិត៖

ប្រសិនបើអ្នកជ្រើសរើសបោះឆ្នោតពីក្រោមបន្ទាត់ដិត៖

1. **សូមសរសេរលេខ '1' នៅក្នុងប្រអប់ក្បែរបេក្ខជនដែលជាជម្រើសទីមួយរបស់អ្នក។**
2. **សូមសរសេរលេខ '2' នៅក្បែរបេក្ខជនដែលជាជម្រើសទីពីររបស់អ្នក។**
3. **សូមសរសេរលេខ 3, 4, 5, 6 នៅក្បែរបេក្ខជនផ្សេងទៀតនៃជម្រើសរបស់អ្នក រហូតដល់អ្នកបានជ្រើសរើសបាន*យ៉ាងតិច 12 បេក្ខជន*។**

អ្នកអាចជ្រើសរើសដាក់ចំនួនបានច្រើនជាង 12 បេក្ខជន។

# តើមានអ្វីកើតឡើងប្រសិនបើខ្ញុំទៅកន្លែងបោះឆ្នោតមិនបាន?

ប្រសិនបើអ្នកទៅកន្លែងបោះឆ្នោតមិនបាន ឬប្រសិនបើអ្នកនឹងស្ថិតនៅក្រៅរដ្ឋ មានវិធីផ្សេងទៀតដើម្បីបោះឆ្នោត។



## ការបោះឆ្នោតតាមប្រៃសណីយ៍

អ្នកអាចស្នើសុំឱ្យគេផ្ញើសន្លឹកឆ្នោតទៅអ្នក ដោយបំពេញទម្រង់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍។
វិធីនេះអាចធ្វើទៅបាននៅ**ប្រហែលប្រាំមួយសប្តាហ៍** មុនការបោះឆ្នោត។

**សូមចូលមើលវេបសាយរបស់យើងនៅ ecsa.sa.gov.au** **ហៅទូរសព្ទឥតគិតថ្លៃទៅលេខ៖ 1300 655 232**

គណៈកម្មការរៀបចំការបោះឆ្នោតរដ្ឋអូស្ត្រាលីខាងត្បូងនឹងដំណើរការពាក្យសុំរបស់អ្នក ហើយចាប់ផ្តើមផ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍ប្រហែលពីរសប្តាហ៍មុនការបោះឆ្នោត។

**សម្រាប់អ្នកដែលនៅក្រៅរដ្ឋអូស្ត្រាលីខាងត្បូង៖** ថ្ងៃផុតកំណត់ដើម្បីស្នើសុំបោះឆ្នោតតាមប្រៃសណីយ៍គឺ 8 ថ្ងៃមុនថ្ងៃបោះឆ្នោត។

**សម្រាប់អ្នកដែលរស់នៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង៖** ថ្ងៃផុតកំណត់ដើម្បីស្នើសុំបោះឆ្នោតតាមប្រៃសណីយ៍គឺ 4 ថ្ងៃមុនថ្ងៃបោះឆ្នោត។

នៅពេលអ្នកទទួលបានសន្លឹកឆ្នោតរបស់អ្នកហើយ សូមបំពេញ រួចផ្ញើវាមកវិញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

បុគ្គលិករៀបចំការបោះឆ្នោតនឹងចុះទៅតាមបណ្តាមន្ទីរពេទ្យ និងមណ្ឌលថែទាំមួយចំនួននៅមុន និងនៅថ្ងៃបោះឆ្នោត។

## ការបោះឆ្នោតប្រសិនបើស្ថិតនៅក្នុងរដ្ឋផ្សេងទៀត

នឹងមានមណ្ឌលបោះឆ្នោតមុនពេលកំណត់នៅគ្រប់រដ្ឋធានីនៃប្រទេសអូស្ត្រាលី។ សូមហៅទូរសព្ទមកយើង ឬចូលទៅកាន់វេបសាយរបស់យើង ដើម្បីមើលទីតាំងនៃមណ្ឌលបោះឆ្នោតមុនពេលកំណត់នានា។

**សូមចូលមើលវេបសាយរបស់យើងនៅ ecsa.sa.gov.au** **ហៅទូរសព្ទឥតគិតថ្លៃទៅលេខ៖ 1300 655 232**

## ការបោះឆ្នោតតាមទូរសព្ទសម្រាប់អ្នកមានគំហើញចុះខ្សោយ និងការអន់ខ្សោយចលនា

ជំនួយសម្រាប់ការបោះឆ្នោតតាមទូរសព្ទ ឥឡូវនេះក៏មានសម្រាប់អ្នកមានកម្សោយចលនា ឬអ្នកបោះឆ្នោតដែលពិការភ្នែក ឬមានគំហើញចុះខ្សោយផងដែរ។

**តើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ទេ?**
ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ សូមទូរសព្ទទៅសេវាកម្មបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ (TIS National) តាមលេខ 131 450 ហើយស្នើសុំឱ្យភ្ជាប់ទៅគណៈកម្មការរៀបចំបោះឆ្នោតរដ្ឋអូស្ត្រាលីខាងត្បូងតាមលេខ 1300 655 232។

**ម៉ោងបើកធ្វើការ៖ ចន្ទ-សុក្រ | 9:00 ព្រឹក ដល់ 5:00 ល្ងាច**



**សំខាន់ - ការបោះឆ្នោតគឺជាកាតព្វកិច្ច។ អ្នកអាចនឹងត្រូវបានផាកពិន័យ ប្រសិនបើអ្នកមិនបោះឆ្នោត។**



**សូមទាក់ទង ECSA តាមទូរសព្ទលេខ 1300 655 232 ប្រសិនបើអ្នកមិនអាចបោះឆ្នោតបានទេ។**